# ក្រុមគុម្ពលទទួលបន្ទុកចុងផ្លូវទឹកស្ទឹងខូវ៉មមីស
# វិធីសាស្ត្រដែលត្រូវបានស្នើសុំនិងសេចក្តីព្រាងនីតិវិធីប្រតិបត្តិ

<u>សេចក្តីព្រាង</u> v. 1-20-21

## 1. ប្រវត្តិ

**<u>A. ការសំអាតទីតាំងកខ្វក់នៅតាមចុងផ្លូវទឹកស្ទឹងខូវ៉មមីស</u>**

ទីតាំងកខ្វក់នៅតាមចុងផ្លូវទឹកស្ទឹងខូវ៉មមីសគឺជាទីតាំងស្ទឹងតែមួយគត់នៅក្នុងទីក្រុងស៊ីងថុលដែលមានចំងាយ ៥ មែល៍ គឺស្ទឹងខូវ៉មមីស។  ស្ទឹងវាហូរកាត់រវាង Georgtown និង South Park ហើយនិងឆ្លងកាត់តាមតំបន់ឧស្សាហកម្មហ៍នៃទីក្រុងស៊ីឯថុល ចូលទៅឆ្នេ Elliot Bay ។ ទីភ្នាក់ងារការពារបរិស្ថាន (EPA) បានប្រកាសថា ចុងផ្លូវទឹកស្ទឹងខូវ៉មមីសគឺជាទី “តាំងមានជាតិកខ្វក់” នៅក្នុងឆ្នាំ 2001 នេះមានន័យថា វាគ្រប់លក្ខណៈសម្បត្តិសម្រាប់កម្មវិធីសំអាតពិេសសរបស់សហព័ន្ធដោយសារវាមាន កម្រិតជាតិកខ្វក់ដ៏ធ្ងន់ធ្ងរ។ នៅក្នុងឆ្នាំ 2014 ទីភ្នាក់ងារ EPA បានបញ្ចប់គម្រោងសំអាតចុងក្រោយសម្រាប់ទីតាំងនេះ ដែលត្រូវបានគេហៅគម្រោងនេះថា “កំណត់ត្រាសម្រេចចិត្ត”។

**<u>B. ភពកំណើតរបស់ក្រុមគុម្ពលទទួលបន្ទុកចុងផ្លូវទឹកស្ទឹងខូវ៉មមីស</u>**

មាត្រាលេខ 13.2.8 នៃកំណត់ត្រាសម្រេចចិត្ត (ROD) ថ្លែងថា៖ ៉ កង្វល់អំពីយុត្តិធម៌បរិស្ថាននឹងត្រូវបានដោះស្រាយជាមុននិងក្នុងអំឡុងពេល ហើយនិងក្រោយការអនុវត្តនៃវិធីសាស្ត្រតាមរយៈមធ្យោ បាយនានាដែលរួមមានទាំង ... ការបន្តចូលរួមសហគមន៍តាមរយៈការរចនាគម្រោងសំអាតនិងការអនុវត្តនៃ ផែនការសំអាត រួមទាំងការកោះប្រជុំក្រុមប្រឹក្សាដែលជាមធ្យោបាយសម្រាប់សហគមន៍ដែលរងផលប៉ះ ពាល់និងមូលដ្ឋានដើម្បីធ្វើការរួមគ្នាលើការដោះស្រាយផលប៉ះពាល់ពីការសំអាតមកលើសហគមន៍ដែលរងផលប៉ះពាល់” (បញ្ជាក់បន្ថែម) ។

.

នៅឆ្នាំ 2015-2016 ក្នុងបទសម្ភាសន៍ដែលនាំអោយមានការធ្វើបច្ចុប្បន្នភាពនៃផែនការពាក់ព័ន្ធសហគមន៍សម្រាប់ការសំអាតចុងផ្លូវទឹកស្ទឹងខូវ៉មមីស ទីភ្នាក់ងារ EPA បានសួរអ្នកចូលរួមបទសម្ភាសន៍អំពីគោលបំណងនិងទម្រង់នៃក្រុមប្រឹក្សាដែលតម្រូវដោយកំណត់ត្រាសម្រេចចិត្ត។ ជាទូទៅ EPA បានស្តាប់ឮចំណុចធំៗពីរគឺ៖  (1) ក្រុម DRCC/TAG គួរបន្តមុខងារជាក្រុមប្រឹក្សាសហគមន៍ (CAG) សម្រាប់ទីតាំងសំអាតនេះ ហើយ (2) ចាំបាច់ត្រូវមានក្រុមបន្ថែមដែលមានសមាជិកទូលំទូលាយជាងក្រុម DRCC/CAG ដើម្បីផ្តល់អនុសាសន៍ទៅ EPA ។

ដោយសារលទ្ធផលនៃការសំណូមពររបស់អ្នកចូលរួមបទសម្ភាសន៍ EPA នឹងបន្តធ្វើការជាមួយក្រុម DRCC / TAG ជាក្រុមប្រឹក្សាសហគមន៍។  ប៉ុន្តែ EPA ក៏នឹងរៀបចំកិច្ចប្រជុំគុម្ពលស្តីអំពីចុងផ្លូវទឹកឌុវ៉មមីស (ក្រុមគុម្ពល) ដែលនឹងមានសមាជិកទូលំទូលាយជាងក្រុម DRCC / TAG ។ គួរកត់សម្គាល់ថាក្រុមគុម្ពលនឹងរួមបញ្ចូលពួក PRPs ដូចជា King County, ទីក្រុង Seattle, កំពង់ផែ Seattle, ក្រុមហ៊ុន Boeing និងអាជីវកម្មផ្សេងទៀតដែលបានចុះក្នុងបញ្ជីរបស់ PRPs ។ សមាជិកទូលំទូលាយនេះនឹងជួយឱ្យមានផលប្រយោជន៍ជាច្រើនដើម្បីរួមគ្នាផ្តល់អនុសាសន៍ទៅ EPA ក្នុងកំឡុងពេលរៀបចំនិងអនុវត្តការសម្អាត។

ចាប់ពីខែកុម្ភៈដល់ខែសីហាឆ្នាំ 2017 ក្រុមតូចមួយនៃសមាជិកដែលមានសក្តានុពលនៃក្រុមគុម្ពលទទួលបន្ទុកចុងផ្លូវទឹកស្ទឹងខូវ៉មមីស បានជួបគ្នាជា ៉គណៈកម្មាធិការរៀបចំ”

ដើម្បីធ្វើសេចក្តីព្រាងពីនីតិវិធីប្រតិបត្តិការទាំងនេះសម្រាប់អោយក្រុមតុម្ងលពិនិត្យនិងអនុម័តនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ពួកគេ។ សូមមើលសេចក្តីបន្ថែម A សម្រាប់បញ្ជីសមាជិកគណៈកម្មាធិការរៀបចំ។ ចាប់ពីឆ្នាំ 2017-2018 អ្នកសម្របសម្រួលភាគីទីបីអព្យាក្រឹត (ក្រុមហ៊ុន Triangle Associates) បានសម្ភាសអ្នកដែលអាចចូលរួមជាសមាជិកក្រុមតុម្ងលជាច្រើននាក់ ហើយនិងស្នើសុំការឆ្លើយតបរបស់ពួកគេលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិការ (សូមមើលសេចក្តីបន្ថែម B សម្រាប់បញ្ជីឈ្មោះអ្នកចូលរួមបទសម្ភាសន៍) ។ ក្នុងអំឡុងពេលប្រជុំលើកដំបូង សមាជិកតុម្ងលបានពិនិត្យមើលកំណែថ្មីនៃ សេចក្តីព្រាងនីតិវិធីប្រតិបត្តិការដែលរួមមានការផ្តល់យោបល់ពីការសម្ភាសន៍របស់ក្រុមហ៊ុន Triangle ។

## 2. គោលបំណងនិងគោលការណ៍នៃក្រុមតុម្ងល

**A. គោលបំណង**

គោលបំណងក្រុមតុម្ងលគឺដើម្បីៈ

- ស្វែងរកដំណោះស្រាយប្រកបដោយមានភាពច្នៃប្រឌិតដើម្បីកាត់បន្ថយផលប៉ះពាល់នៃការសាងសងគម្រោងចុងផ្លូវទឹកស្ទឹងឌូវ៉មមីស។ (ឧទាហរណ៍ ដូចជា ចរាចរណ៍ សម្លេងថ្លង់រំខាន ភ្លើង ផលប៉ះពាល់លើសកម្មភាពរបស់កុលសម្ព័ន្ធ គុណភាពខ្យល់ គុណភាពទឹក អាជីវកម្មនៅតាមមាត់សមុទ្រ ការនេសាទ ការកំសាន្ត និងគុណភាពជីវិត) ។

- ផ្តល់អនុសាសន៍ទៅ EPA ព្រមទាំងទីភ្នាក់ងារនិងអង្គការដទៃទៀត ដើម្បីអភិវឌ្ឍការរចនា និងការអនុវត្តការសម្អាតឱ្យបានជោគជ័យ។
- ដើរតួជាអ្នកអព្យាក្រឹត និងមានតម្លាភាពសម្រាប់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ - កុលសម្ព័ន្ធ អ្នកស្រុក អ្នកជំនួញឧស្សាហកម្ម ក្រុមអ្នកធ្វើការក្រុម អ្នកជិតខាង ទីភ្នាក់ងាររដ្ឋាភិបាល អ្នកប្រើប្រាស់ផ្លូវទឹក អ្នកនេសាទ និងអ្នកដទៃទៀត។

- ដើរតួជាមធ្យោបាយនៃការផ្តល់នូវការទាក់ទងមានភាពស្មោះត្រង់ ការយល់ដឹង និងព័ត៌មានស្តីពីប្រធានបទទាក់ទងនឹងការសម្អាតទីតាំងដែលមានជាតិកខ្វក់ ។
- ស្គាល់ឱកាសសម្រាប់មធ្យោបាយដែលមានសក្តានុពលដើម្បីផ្តល់ផលប្រយោជន៍ដល់អ្នកជិតខាង និងសហគមន៍ដែលរងផលប៉ះពាល់ពីការសំអាតដែលថិតនៅក្នុងទីតាំងនៃទីកន្លែងសម្អាតជាតិកខ្វក់។ ហើយនិង
- ព្យាយាមអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធនិងទីភ្នាក់ងារទាំងអស់ធ្វើប្រតិបត្តិការក្រោមសំណុំតែមួយ។

**B. ការកំណត់**

តាមគំរោងការចូលរួមរបស់សហគមន៍ ក្រុមតុម្ងលនឹងមានកំរិតជាក់លាក់។ ឧទាហរណ៍ ក្រុមតុម្ងលមិនមែនមានបំណងមកជំនួសៈ

- មុខងាររបស់ក្រុម DRCC/TAG ជាតួរនាទីក្រុមប្រឹក្សាសហគមន៍ (CAG) ទេ;
- ការពិគ្រោះយោបល់រវាងរដ្ឋាភិបាលនិងកុលសម្ព័ន្ធរ Suquamish, Muckleshoot ឬ Yakama Tribes;
- ការចូលរួមផ្លូវការជាសាធារណៈនិងឱកាសបញ្ចេញយោបល់ជាសាធារណៈដែល EPA និងបរិស្ថានវិទ្យានឹងធ្វើ។
- ក្រុមបរិភោគតែអាហារសមុទ្រដែលល្អសម្រាប់សុខភាព; ឬ

- កុលសម្ព័ន្ធ អ្នកទទួលខុសត្រូវ និងក្រុមសហគមន៍។ ការសំរេចចិត្តរបស់ EPA ទាក់ទងនឹង កុលសម្ព័ន្ធ អ្នកទទួលខុសត្រូវ និងក្រុមបរិភោគតែអាហារសមុទ្រដែលល្អសម្រាប់សុខភាព នឹង ពិចារណាលើការផ្តល់មតិពីក្រុមតុមូល។ យ៉ាងតិចបំផុត EPA នឹងបន្តអនុវត្តតាមតម្រូវការ និង គោលនយោបាយច្បាប់។ ការសំរេចចិត្តនឹងពិចារណាលើការប្រើប្រាស់ធនធានរបស់ EPA ដ៏ល្អ បំផុត។

**C.** <u>គោលការ</u>
កិច្ចពិភាក្សាតុមូលនឹងដំណើរការស្របតាមគោលការណ៍ដូចខាងក្រោម៖ ការមានតុល្យភាពអំណាច មាន តម្លាភាព មានប្រសិទ្ធភាព មានដំណោះស្រាយសមរម្យ និងយុត្តិធម៌និងសមធម៌សម្រាប់សហគមន៍ ទាំងមូល។

**D.** <u>ការបញ្ឈប់</u>
កិច្ចពិភាក្សាតុមូលនេះមានគោលបំណងផ្តល់នូវមតិយោបល់ទៅ EPA ក្នុងអំឡុងពេលធ្វើការសម្អាតនៅ តាមទីតាំងដែលមានជាតិកខ្វក់។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើក្រុមតុមូលមិនបានបំពេញ តាម តម្រូវការរបស់ EPA ឬ ប្រសិនបើថវិកា ច្បាប់ ឬមានបញ្ហាអ្វីផ្សេងទៀតកើតឡើង EPA ប្រហែលជាអាច នឹងមានសិទ្ធសម្រេចបន្តតួនាទីរបស់ខ្លួនជាអ្នកកោះហៅអោយចូលរួមអង្គប្រជុំតុមូល។ នៅក្នុង ព្រឹត្តិ ការណ៍នេះ EPA នឹងផ្តល់ដំណឹងឱ្យបានឆាប់ជាទីបំផុតដែលអាចធ្វើបានជូនទៅសមាជិកតុមូល និង ក្រុមប្រជុំអោយបាននឹង។ សូមកត់សម្គាល់ថា កិច្ចពិភាក្សាតុមូលប្រហែលជាអាចបន្តធ្វើកិច្ច ប្រជុំដោយ ខ្លួនឯងផ្ទាល់ដោយមិនចាំបាច់មាន EPA ធ្វើជាអ្នកកោះហៅអោយចូលរួមអង្គ ប្រជុំជាផ្លូវ ការឡើយ។

## 3. សមាជិកក្រុមតុមូល

កិច្ចពិភាក្សាក្រុមតុមូលនឹងមានរាប់បញ្ចូលអាសនៈសម្រាប់ EPA ជាអ្នកកោះហៅអោយចូលរួមអង្គប្រជុំ បូកនឹងប្រមាណ ៥-១០ អាសនៈសម្រាប់សមាជិកតុមូល។ សមាជិកតុមូលនឹងមាន:

- ក្រុមអង្គប្រជុំ គឺជាអ្នកដឹកនាំអ្នកតំណាងឱ្យក្រុមប្រជុំដែលបង្កើតឡើងដោយសមាជិក ដែលមានផលប្រយោជន៍រួម។
- កុលសម្ព័ន្ធនីមួយៗដែលត្រូវបានទទួលស្គាល់ពីសហព័ន្ធ គឺជាអ្នកដែលជ្រើសរើសចូលរួម។
- សមាជិកធនធានដែលមានតួនាទីចម្បងក្នុងការផ្តល់ព័ត៍មាន (ជាជាងការផ្តល់អនុសាសន៍) ទៅក្រុមតុមូល។
- ករណីចាំបាច់មួយ ឬ មានអាសានៈទំនេរ។ សូមមើលរូបក្រាហ្វិចនៅទំព័រទី ៦ សម្រាប់ការបង្ហាញ អំពីសមាជិកក្រុមតុមូល។

**A. <u>EPA ជាអ្នកកោះប្រជុំតុមូល</u>**

**B.** EPA នឹងចូលរួមរាល់ការប្រជុំដែលបានកំណត់ពេលទៀងទាត់។ ពួកគេនឹងចូលរួមនិងធ្វើរបាយ ការណ៍សង្ខេបស្តីពីការអប់រំពីអតីតកាលនិងបច្ចុប្បន្ននៃទីតាំងសម្អាតដើម្បីធានាបាននូវចំនេះដឹង រួមនៃចំណុចបញ្ហាសំខាន់ៗ ខាងបច្ចេកវិទ្យានិងដំណើរការសម្អាតទីតាំងកខ្វក់ ។ EPA នឹងផ្តល់ជូន សមាជិកតុមូលនូវប្រធានបទនិងសំណើសម្រាប់ការពិចារណារបស់ពួកគេមុនកិច្ចប្រជុំតុមូល។ EPA នឹងជួយគណៈកម្មាធិការដឹកនាំ (សូមមើលផ្នែក 7.B) ក្នុងការរៀបចំរបៀបវារៈអង្គប្រជុំតុមូល និង ផែនការការងារ។ EPA នឹងឆ្លើយតបទៅនឹងសកម្មភាពដែលមានលក្ខណៈច្បាស់ លាស់ចំៗនិង ទាន់

ពេលវេលា។ EPA នឹងពិចារណាឱ្យបានម៉ឺងម៉ាត់និងដោយស្មោះត្រង់ពិចារណាលើអនុសាសន៍របស់ក្រុមគុមូលនិងផ្តល់ចម្លើយឆ្លើយតបដោយផ្ទាល់មាត់ចំពោះមតិនោះ (សូមមើលផ្នែក 6.B) ដូច្នោះក្រុមគុមូលអាចមើលថា តើមតិរបស់ពួកគេត្រូវបានយកមកពិចារណាដែរឬអត់។ EPA នឹងខិតខំពេញមួយដំណើរការ ដើម្បីចូលរួមការសន្ទនាប្រកបដោយមានការគោរព មានអត្ថប្រយោជន៍ជាមួយសមាជិកគុមូល និងទទួលយកនូវអនុសាសន៍របស់ក្រុមគុមូល។

**C.** <u>ក្រុមធ្វើអង្គប្រជុំ</u>

ក្រុមធ្វើអង្គប្រជុំ គឺជាក្រុមរងដែលរួមមានអ្នកតំណាងដែលបានកំណត់អត្តសញ្ញាណដែលមានចំ ណាប់អារម្មណ៍ស្រដៀងគ្នា។ គោលបំណងនៃការប្រជុំនេះគឺដើម្បីឱ្យក្រុមដែលមានចំណាប់អារម្មណ៍ពិ ភាក្សាគ្នាអំពីបញ្ហានិងអនុសាសន៍នានាមុនពេលកិច្ចប្រជុំគុមូលកាន់តែធំ។

- ក្រុមធ្វើអង្គប្រជុំ ប្រហែលជាអាចរាប់បញ្ចូលៈ
    - **ក្រុមអង្គប្រជុំទីប្រឹក្សាសហគមន៍** (CAG) (**ឧទាហរណ៍ ដូចជា សម្ព័ន្ធភាពសម្អាតចុងផ្លូវទឹកស្ទឹងខូវ៉មមីស/ ក្រុមប្រឹក្សាបច្ចេកទេស** (DRCC / TAG) **និងសមាជិករបស់គេ**)
    - ពួកដែលមិនមែនជាក្រុមអង្គប្រជុំទីប្រឹក្សាសហគមន៍ (**ឧទាហរណ៍ ដូចជា សមាជិកសហគមន៍ សមាគមក្នុងភូមិ និងអង្គមានមូលដ្ឋានក្នុងសហគមន៍ដែលមិនមែនជាផ្នែក នៃក្រុម** DRCC / TAG))
    - ភាគីដែលអាចទទួលខុសត្រូវ (PRP) ផ្នែក**រដ្ឋាភិបាល** (ឧទាហរណ៍ ដូចជា **ទីភ្នាក់ងារ រដ្ឋាភិបាលក្នុងតំបន់ដែលបានចុះឈ្មោះក្នុងបញ្ជីរបស់** PRP **រួមទាំងក្រសួងផ្តល់សេវា កម្មសាធារណៈក្រុងស៊ីឯថុល** ក្រសួងសម្អាតទឹកស្អុយក្នុងតំបន់ King County **និងកំពង់ ផែក្រុងស៊ីឯថុល** Seattle)
    - ពួកដែលមិនមែនជាក្រុមជាប់ពាក់ព័ន្ធទទួលខុសត្រូវផ្នែក**រដ្ឋាភិបាល** (ឧទាហរណ៍ ដូចជា **ទីភ្នាក់ងាររដ្ឋាភិបាលក្នុងតំបន់ដែលមិនមានចុះឈ្មោះក្នុងបញ្ជីរបស់** PRP **រួមទាំងភ្នាក់ងារសុខភាពនិងបរិស្ថាន**)
    - ក្រុមដែលមានចំណាប់អារម្មណ៍ទទួលខុសត្រូវខាងជីវកម្ម / **ឧស្សាហកម្ម** / **ការងារ** (ឧទាហរន៍ ដូចជា ក្រុមអាជីវកម្ម **ឧស្សាហកម្ម និងក្រុមការងារដែលប្រហែលជាបាន ចុះក្នុងបញ្ជីរបស់** PRPs)
    - ពួកដែលមិនមែនជាក្រុមមានចំណាប់អារម្មណ៍ខាងជីវកម្ម / **ឧស្សាហកម្ម** / **ការងារ** (ឧទាហរណ៍ ដូចជា អាជីវកម្មខ្នាតតូចដែលមិនបានចុះឈ្មោះក្នុងបញ្ជីរបស់ PRP តែត្រូវបានរងផលប៉ះពាល់ពីការសម្អាត ដូចជាផ្សាលក់ឥវ៉ាន់ ភោជនីយដ្ឋាន និងហាងលក់ដូរ)
    - អ្នកប្រើប្រាស់ស្ទឹងសម្រាប់លំហែកាយ (ដូចជា ក្លឹបនាវា អ្នកមានទីលំនៅលើទឹក ក្លឹបចែវទូក ក្លឹបអ៊ុំទូក)
    - **អ្នកនេសាទ** (អ្នកដែល**នេសាទនៅតាមដងស្ទឹងខូវ៉មមីស**)។ សូមកត់**សម្គាល់: ក្រុមគុមូលនេះ ខុសគ្នាពីកម្មវិធីគ្រប់គ្រងស្ថាប័នរបស់** EPA **និងគណៈកម្មាធិការ ដឹកនាំសហគមន៍ដែលពាក់ព័ន្ធ។**
- សមជិកក្រុមអង្គប្រជុំៈ ក្រុមអង្គប្រជុំនី**មួយៗនឹងបង្កើតអោយមានលក្ខណៈវិនិច្ឆ័យសម្រាប់ អ្នកចូលរួមជាសមាជិក។ លក្ខណៈវិនិច្ឆ័យសម្រាប់អ្នកចូលរួមជាសមាជិកនៅក្នុង ក្រុមអង្គ ប្រជុំនីមួយៗនឹងត្រូវបានចងក្រងជាឯកសារនៅពេលត្រូវបានបង្កើតឡើង។ នេះក៏អាច រួមបញ្ចូលទាំងពេលវេលាសម្រាប់ពេលដែលពាក្យសុំចូលជាសមាជិកក្នុងក្រុមអង្គប្រជុំនឹងត្រូវបានទទួលយក។** មេដឹកនាំក្រុមអង្គប្រជុំ**នីមួយៗគួរធ្វើការជាមួយក្រុមអង្គប្រជុំ ដើម្បីកំណត់ នូវអ្វី ដែលអាច**

**បង្កើតជាអង្គប្រជុំនិងរបៀបដែលក្រុមអង្គប្រជុំនោះគ្រប់គ្រងដោយខ្លួនឯងក្នុងការឈានទៅដល់អនុសាសន៍ទាំងនេះ។**

- មេដឹកនាំៈ ក្រុមអង្គប្រជុំ**នីមួយៗនឹងមានអ្នកដឹកនាំម្នាក់ (ឬច្រើននាក់) ដែលមានតួនាទីសំខាន់ក្នុងការទំនាក់ទំនងជាមួយ** EPA **និងអ្នកសម្របសម្រួល។** មេដឹកនាំក្រុម អង្គប្រ ជុំនឹង **ទទួលខុសត្រូវក្នុងការចូលរួមក្នុងគណៈកម្មាធិការដឹកនាំក្រុមតុមូល (សូមមើលផ្នែក** 6.B ) **និងរក្សាទំនាក់ទំនងជាមួយសមាជិករបស់ខ្លួន។** ក្រុមអង្គប្រជុំ**នីមួយៗនឹងកំណត់ពី របៀប ដែលពួកគេជ្រើសរើសមេដឹកនាំនឹងអាណាត់របស់ពួកគេ។** ក្រុមអង្គប្រជុំទាំអស់**អាចទាក់ទង អ្នកសម្របសម្រួលភាគីទីបីអព្យាក្រឹតរបស់ក្រុមតុមូលដើម្បីទទួលបានការណែនាំអំពីរបៀបបង្កើតពិធីត្រឹមត្រូវដើម្បីជ្រើសរើសមេដឹកនាំ ក្នុងចំណោមប្រធានបទផ្សេងៗទៀត។**

- ការសម្របសម្រួលៈ ក្រុមអង្គប្រជុំប្រហែលជាត្រូវការការគាំទ្រសម្របសម្រួលនៅពេលសមា ជិកសម្រេចចិត្តលើការជ្រើសរើសមេដឹកនាំ របៀបដែលពួកគេត្រូវរៀប ចំដោយខ្លួនឯង និងពិធីទំនាក់ទំនងគ្នា។ ក្រុមអង្គប្រជុំក៏ អាចសំរេចចិត្តរកការសម្របសម្រួល ពីខាងក្រៅប្រ សិនបើចាំបាច់។

- ការទំនាក់ទំនងគ្នាៈ ក្រុមអង្គប្រជុំនីមួយៗនឹងប្រាស្រ័យទាក់ទងគ្នាជាមុនរវាងកិច្ចប្រជុំតុមូលដើម្បីបង្កើតជាអនុសាសន៍ផ្ទាល់ខ្លួន។ គេបានទូមានឱ្យមានការជួបជុំគ្នាផ្ទាល់មុខឬតាមទូរ ស័ព្ទមុនពេលកិច្ចប្រជុំតុមូលកាន់តែធំ។ ក្រុមអង្គប្រជុំនីមួយៗត្រូវបានលើកទឹកចិត្តឱ្យ នាំយក ទស្សនៈតែមួយគត់ដើម្បីពិភាក្សាគ្នាក្នុងកិច្ចប្រជុំតុមូល។ ប្រសិនបើក្រុមអង្គប្រជុំមួយមិន អាចយល់ព្រមលើអនុសាសន៍ណាមួយទេ គេប្រហែលជាអាចលើកយកទស្សនៈជា ច្រើនទៀតមក ពិភាក្សាគ្នា។ ក្រុមអង្គប្រជុំទាំងអស់ប្រហែលជាអាចពិភាក្សាគ្នាមុនពេលចូលរួមកិច្ចប្រជុំតុមូល ក៏ប៉ុន្តែមិនចាំបាច់ទេ។

**C.** <u>កុលសម្ព័ន្ធៈ</u> កុលសម្ព័ន្ធដែលត្រូវបានទទួលស្គាល់ដោយសហព័ន្ធដែលអាចរងផលប៉ះពាល់ដោយការសម្អាត (អាច ស្ម័គ្រចិត្តចូលរួម) ។ EPA បានអញ្ជើញកុលសម្ព័ន្ធ Suquamish Tribe, Muckleshoot Tribe និង Yakama Nation មកចូលរួមក្នុងកិច្ចប្រជុំតុមូល។ ការចូលរួមក្នុងតុមូលរបស់កុលសម្ព័ន្ធទាំងនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិពិគ្រោះយោបល់រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាលជាមួយ EPA ឡើយ។

**D.** ធនធានសមាជិកៈ ធនធានសមាជិកផ្តល់ព័ត៌មានដល់សមាជិកតុមូលនិង EPA ប៉ុន្តែពួកគេមិនបង្កើតអនុសាសន៍ដើម្បីអោយ EPA យកមកពិចារណាទេ។ ធនធានសមាជិកអាចជាសមាជិកដែលរង់ចាំឬស្នើសុំប្រធានបទជាក់លាក់។ ធនធានសមាជិកដែលនៅរង់ចាំនឹងត្រូវបានកំណត់អត្តសញ្ញាណបន្ទាប់ពីកិច្ចប្រជុំតុមូល។ EPA អាចអញ្ជើញធនធានសមាជិកឱ្យមកចូលរួមកិច្ច ប្រជុំ ឬ សមាជិកតុមូលអាចស្នើសុំឱ្យ EPA ញើញធនធានសមាជិកឱ្យមកចូលរួម។ មានធនធានសមាជិកដែលមានសក្តានុពលមួយចំនួនដូចមានចែងនៅខាងក្រោម។

- <u>សមាជិកក្រុមប្រឹក្សាឆ្នេរ Elliot Bay</u> មិនមែនជាសមាជិករបស់ក្រុមអង្គប្រជុំដទៃទៀត ឬតំណាងដោយអាសនៈផ្សេងទៀត។

- <u>ទីភ្នាក់ងារសហព័ន្ធផ្សេងទៀត </u>ដូចជាអង្គភាពវិស្វកម្មកងទ័ពសហរដ្ឋអាមេរិក ឬ ការស្ទង់មតិភូគព្ភសាស្ត្រសហរដ្ឋអាមេរិក។

- <u>ទីភ្នាក់ងាររដ្ឋផ្សេងទៀត </u>ដូចជាក្រសួងបរិស្ថាននៃរដ្ឋវ៉ាស៊ីងតោន ក្រសួងសុខាភិបាលនៃ រដ្ឋវ៉ាស៊ីងតោន ក្រសួងធនធានធម្មជាតិនៃរដ្ឋវ៉ាស៊ីងតោន និងនាយកដ្ឋានត្រីនិងសត្វព្រៃ នៃវ៉ាស៊ីងតោន។.

- ទីភ្នាក់ងាររដ្ឋាភិបាលក្នុងតំបន់ ដែលមិនមែនជាផ្នែកនៃ PRP ឬមិនមែនជា PRP របស់រដ្ឋាភិបាលក្រុមអង្គប្រជុំមូលដ្ឋាន។
- ស្ថាប័នអប់រំ ដូចជាកម្មវិធីស្រាវជ្រាវទីតាំងមានជាតិកខ្វក់របស់សាកលវិទ្យាល័យវ៉ាស៊ីងតោន។

**E.** កិច្ចចាំបាច់: នេះអាចរួមបញ្ចូលទាំងសមាជិកដែលចាប់អារម្មណ៍របស់សាធារណជនឬអង្គភាពផ្សេងទៀតដែលបានយល់ព្រមដោយក្រុមគុម្ពល។ សមាជិកគុម្ពលនឹងមានឱកាសពិភាក្សាអំពីការបន្ថែមសមាជិក ដែលចាំចាប់មុនពេលសមាជិកដ៏ចាំបាច់នេះចូលរួមក្នុងក្រុមគុម្ពលជាផ្លូវការ។

## 4. ការពិចារណាផ្សេងៗទៀតរបស់ក្រុមគុម្ពល

A. សំណង៖ ទីប្រឹក្សាច្បាប់របស់ EPA បានបញ្ជាក់ថា EPA មិនត្រូវបានអនុញ្ញាតិឱ្យផ្តល់ប្រាក់កាសដល់សមាជិកសហគមន៍សម្រាប់ការចូលរួមរបស់ពួកគេឡើយ។ អង្គភាពផ្សេងទៀត (ឧទាហរណ៍ ដូចជា ទីភ្នាក់ងាររដ្ឋាភិបាលមូលនិធិ អង្គការមិនរកប្រាក់ចំណេញ អាជីវកម្មផ្សេងៗទៀត ។ ល។ ) អាចផ្តល់ ជាថវិកាដល់ការចូលរួមរបស់សហគមន៍ដោយឯករាជ្យប៉ុន្តែ EPA មិនអាចណែនាំឬលើកទឹកចិត្តអង្គភាពឱ្យធ្វើរបៀបនេះឬពាក់ព័ន្ធនឹងការសម្រេចចិត្តអំពីសំណងឡើយ។ អង្គភាពផ្សេងទៀតដែលចូលរួមនៅក្នុងក្រុមគុម្ពលនឹងធ្វើការដើម្បីស្វែងរកថវិកាដើម្បីទូទាត់សំណងដល់សមាជិកសហគមន៍ដែលត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការចូលរួមរបស់ពួកគេ។ ប្រសិនបើថវិកាមិនមានសម្រាប់ទ្រទ្រង់ដើមទុនសម្រាប់សមាជិកសហគមន៍ គ្រប់សមាជិកគុម្ពលទាំងអស់នឹងត្រូវជូនដំណឹងជាមុនមុនពួកគេចូលរួមកិច្ចប្រជុំគុម្ពល។ ប្រសិនបើសមាជិកគុម្ពលជ្រើសរើសមិនចូលរួមក្នុងកិច្ចប្រជុំ គុម្ពលដោយគ្មានប្រាក់សំណង EPA នឹងធ្វើការជាមួយសមាជិកគុម្ពលដើម្បីរកវិធី ដែលអាចដោះស្រាយបាន ឬ ប្រសិនបើមិនអាចទទួលយកបានគេនឹងផ្តល់យោបល់អោយរំលាយក្រុមគុម្ពលចោល។ EPA នឹងធ្វើការសំរេចចិត្តពិចារណាលើជំរើសទាំងអស់សំរាប់ការចូលរួមរបស់សាធារណ:ជន ហើយនឹងបន្តទៅមុខទៀតជាមួយនឹងការរចនានិងសកម្មភាពផែនការសម្អាត។

B. ការចូលរួម៖ សមាជិកគុម្ពលនិងសមាជិកសាធារណ:ត្រូវបានលើកទឹកចិត្តឱ្យចូលរួមកិច្ចប្រជុំគុម្ពលយ៉ាងខ្ជាប់ខ្ជួនដើម្បីឱ្យ EPA ទទួលបានការយល់ឃើញរបស់ពួកគេនិងដើម្បីឱ្យពួកគេទទួលបានពត៍មានថ្មីៗ ស្តីអំ ពីផែនការសម្អាត។

C. ការជំនាស់ផលប្រយោជន៍៖ ដើម្បីធានាបាននូវភាពសុចរិតនៃក្រុមគុម្ពលទទួលបន្ទុកសម្អាតចុងផ្លូវទឹកស្ទឹងខ្វរ៉មមីស គឺវា សំខាន់ណាស់ដែលសមាជិកត្រូវបង្ហាញពីទំនាស់ផលប្រយោជន៍។ នេះមានន័យថា សមាជិកគុម្ពល ទាំងអស់និងសមាជិកក្រុមធ្វើអង្គប្រជុំត្រូវបានគេរំពឹងថា នឹងបង្ហាញចំណាប់អារម្មណ៍ណាមួយ (រួមទាំងផលប្រយោជន៍ហិរញ្ញវត្ថុ) ដែលអាចទទួលបានអត្ថប្រយោជន៍ពីអនុសាសន៍គុម្ពលជាក់ លាក់មួយដល់ EPA ។ នេះរាប់បញ្ចូលទាំងអត្ថប្រយោជន៍ផ្ទាល់ដល់សមាជិកគុម្ពលឬអត្ថប្រយោជន៍ ដោយប្រយោលតាមរយ:ក្រុមគ្រួសារជំនួញឬសម្ព័ន្ធភាពផ្សេងទៀត។ សមាជិកគុម្ពលដែលមានទំនាស់ ផលប្រយោជន៍ត្រូវបង្ហាញជាលាយលក្ខណ៍អក្សរទៅ EPA និងសមាជិកគុម្ពលផ្សេងទៀត អំពី លក្ខណ: នៃទំនាស់ផលប្រយោជន៍ដែលអាចកើតឡើង។ កិច្ចពិភាក្សាគុម្ពលនឹងវាយតម្លៃជម្រើសដើម្បី ដោះ ស្រាយទំនាស់ផលប្រយោជន៍តាមរយ:ការកែប្រែបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ចំពោះការចូលរួមរបស់សមាជិកគុម្ពលនិង/ឬ ក្រុមអង្គប្រជុំ។

# កិច្ចប្រជុំតុមូលស្តីពីការសម្អាតចុងផ្លូវទឹកស្ទឹងខូរម៉មីសផ្នែកខាងក្រោមទន្លេ Duwamish

**គោលបំណង៖** ដើម្បីផ្តល់វេទិកាមួយសម្រាប់ភាគីដែលមានចំណាប់អារម្មណ៍ និងភាគីទទួលរងផលប៉ះពាល់ ផ្តល់ដើម្បីផ្តល់អនុសាសន៍ទៅអោយសម្រាប់ EPA យកមកធ្វើការពិចារណានៅក្នុងអំឡុងពេលកម្មវិធីសម្អាតទីតាំងដែលមានជាតិកខ្វក់នៅតាមចុងផ្លូវទឹកស្ទឹងខូរម៉មីស។ផ្នែកខាងក្រោម Lower Duwamish Waterway Superfund។




ចំណុចសំខាន់

**C** ក្រុមធ្វើអង្គប្រជុំ
**S** អាសៈន:
**R** ធនធានសមាជិក
សមាជិក

*សមាជិកសហគមន៍ដែលមិនជាប់ពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាល ឬក្រុមដែលមានចំណាប់អារម្មណ៍ដែលមិនត្រូវបានគេតំណាងអោយនៅក្នុងកិច្ចប្រជុំគាំទ្រសហគមន៍។

**ស្ថាប័នរដ្ឋាភិបាលដែលផ្តល់ព័ត៌មាន ប៉ុន្តែមិនមែនជាអ្នកបង្កើតអនុសាសន៍ រួមទាំង ប៉ុន្តែមិនកំណត់ចំពោះក្រសួងបរិស្ថាននៃរដ្ឋវ៉ាស៊ីងតោននិងផ្សេងទៀតឡើយ។

V. 3/26/21

5. **ផែនការការងារនិងប្រធានបទ** ក្រុមតុម្ភលនឹងលើកយកប្រធានបទនៅក្នុងវិសាលភាពនៃកាសំអាតទីតាំងកខ្វក់នៅតាមចុងផ្លូវទឹកស្ទឹងខូវមមីស។ ក្រុមតុម្ភលនឹងរៀបចំផែនការការងារប្រចាំឆ្នាំ ដើម្បីដឹកនាំការងាររបស់ខ្លួនដើម្បី សម្រេចគោលបំណងដែលបានចែងនៅក្នុង 2A ។ ព័ត៌មានស្ដីពីការអនុវត្តន៍របស់ EPA នឹងមិនត្រូវ បានរាប់បញ្ចូលឡើយ។ កំណត់ត្រា សម្រេចចិត្តលើការសម្អាតចុងផ្លូវទឹកស្ទឹងខូវមមីស គឺជាជម្រើស ចុងក្រោយហើយ ការជ្រើសរើសសំណងមិនមែនជាចំណុចយកចិត្តទុកដាក់របស់ក្រុមតុម្ភលទេ។ ផ្ទុយ ទៅវិញ ក្រុមតុម្ភលនឹងផ្តោតលើបញ្ហាដែលទាក់ទងទៅនឹងការរចនានិងការ អនុវត្តការសាងសង សម្អាត។

EPA ទទួលស្គាល់ថា មានបញ្ហាផ្សេងៗគ្នាជាច្រើនដែលជះឥទ្ធិពលដល់អ្នករស់នៅតំបន់ខូវមមីសដែលស្ថិតនៅក្រៅវិសាលភាពនៃការសំអាតទីតាំងមានជាតិកខ្វក់។ ឧទាហរណ៍ ដូចជា EPA យល់ថា ការសម្អាតនិងការផ្លាស់ប្តូរ ការខ្វះហាងលក់គ្រឿងទេស ការខ្វះស្បៀងអាហារ គ្មានទីតាំងស្អាតគ្រប់គ្រាន់ និងផ្ទះសំបែងកាន់តែថ្លៃទៅៗ គឺសុទ្ធតែជាកង្វល់ធំនៅក្នុងតំបន់ស្ទឹងខូវមមីស។ ទោះយ៉ាងណាក៏ដោយ EPA មិនមានសិទ្ធិអំណាចលើផ្ទះសំបែងនៅតាមមូលដ្ឋាន គោល ការច្បាប់ស្បៀងអាហារ និងការ សម្រេចចិត្តក្នុងទីសាធារណ: ដែលមានន័យថា ប្រធានបទទាំងនេះនឹងមិន ត្រូវបានលើកយក មកពិ ភាក្សាដោយផ្ទាល់ទេនៅក្នុងកិច្ចប្រជុំតុម្ភល។ ដើម្បីគាំទ្រដល់អ្នកដទៃក្នុងការដោះស្រាយបញ្ហា ដែលមាន សារៈសំខាន់សម្រាប់សមាជិកតុម្ភល EPA នឹងបម្រុងទុកកយ:ពេលប្រជុំចំនួន ៣០-៦០ នាទី លើស ពីចំនួនម៉ោងប្រជុំតុម្ភលដើម្បីអនុញ្ញាតឱ្យទីភ្នាក់ងាររដ្ឋាភិបាលក្នុងតំបន់ អង្គភាព អាជីវកម្ម និងអ្នក ដទៃទៀតបន្តផ្តោតលើប្រធានបទទាំងនេះ។

## 6. ផ្តល់អនុសាសន៍ទៅ EPA

**A.** ការផ្តល់អនុសាសន៍

ក្រុមតុម្ភលនឹងមានតួនាទីជាទីប្រឹក្សា មិនមែនជាស្ថាប័នធ្វើការសម្រេចចិត្តទេ។ គ្រប់សមាជិកតុម្ភលទាំងអស់នឹងចូលរួមផ្តល់អនុសាសន៍ទៅ EPA ។ អនុសាសន៍គឺដើម្បីផ្តល់ជាមតិនិងយោបល់ទៅ EPA លើបញ្ហាទាក់ទងនឹងការសំអាតទីតាំងមានជាតិកក្វក់នៅតាមចុងផ្លូវទឹកស្ទឹងខូវមមីស។.

**មុនពេលកិច្ចប្រជុំតុម្ភ មេដឹកនាំក្រុមអង្គប្រជុំ នឹងទទួលបានសេចក្តីសង្ខេបជាលាយលក្ខណ៍ អក្សរ អំពីបញ្ហាដែល EPA កំពុងស្វែងរកអនុសាសន៍ឬការផ្តល់យោបល់។ ក្រុមអង្គប្រជុំនីមួយៗនឹងបង្កើត អនសាសន៍ផ្ទាល់ខ្លួនដើម្បីអោយ EPA យកមកពិចារណា។ ក្រុមតុម្ភលនឹងជួបជុំគ្នាដើម្បីព្យាយាមផ្សះផ្សា អនសាសន៍ទៅជាអនុសាសន៍រួមមួយប្រសិនបើចង់បាន។ ប្រសិនបើមានការមិនចុះសម្រុងគ្នាអ្នក ក្រុម អង្គប្រជុំនីមួយៗ អាចប្រគល់អនុសាសន៍ផ្ទាល់ខ្លួន។ សេចក្តីសង្ខេបនៃកិច្ចប្រជុំនឹងកត់ត្រា នូវអន សាសន៍ដែលមិនឯកភាពគ្នាតាមសំណើរបស់សមាជិកតុម្ភលនីមួយៗ។**

**B.** ការឆ្លើយតបរបស់ **EPA** លើអនុសាសន៍

នៅក្នុងកិច្ចប្រជុំតុម្ភល EPA នឹងផ្តល់ការឆ្លើយតបដោយផ្ទាល់មាត់ចំពោះអនុសាសន៍ដែលត្រូវបាន ផ្តល់ជូននៅក្នុងកិច្ចប្រជុំតុម្ភលកន្លងមក។ ចម្លើយទាំងនេះនឹងត្រូវបានថតនៅក្នុងសេចក្តី សង្ខេប ប្រជុំដែលនឹងត្រូវផ្សព្វផ្សាយជាសាធារណ:នៅលើគេហទំព័រតុម្ភល។

## 7. តួនាទី

**A.** <u>តួនាទីរបស់ទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក</u>
EPA **នឹងចូលរួមនិងប្រលូកក្នុងកិច្ចប្រជុំតុមូលក្នុងនាមជាអ្នកតំណាងកិច្ចប្រជុំដើម្បីធ្វើជា ធនធាន និង ដើម្បីទទួលបានអនុសាសន៍ពីក្រុមតុមូល។ ចំពោះពត៌មានបន្ថែមអំពីតួនាទីរបស់** EPA **សូម មើលផ្នែក** 3A **និង** 6B **។**

**B.** <u>តួនាទីរបស់គណៈកម្មាធិការដឹកនាំ</u>
ខាងក្រោមគឺជាពត៌មានអំពីគោលបំណងនៃគណៈកម្មាធិការដឹកនាំនិងវិធីដែលត្រូវបានបង្កើតឡើង។

- <u>គោលបំណង៖</u> គណៈកម្មាធិការដឹកនាំនឹងសម្របសម្រួលជាមួយ EPA ដើម្បីដឹកនាំការងារតុមូល រួមមានការស្នើសុំប្រធានបទរបៀបវារៈ ការធ្វើសេចក្តីព្រាងរបៀបវារៈប្រជុំ ការរៀបចំផែនការការងារតុមូល និងភារកិច្ចផ្សេងៗទៀតតាមការគ្រោងទុក។ គណៈកម្មាធិការដឹកនាំនឹងជួបគ្នាតាមទូរស័ព្ទឬដោយផ្ទាល់ រហូតដល់ទៅពីរដងមុនពេលកិច្ចប្រជុំតុមូលនីមួយៗ។ សមាជិកគណៈកម្មាធិការដឹកនាំ (ទាំងសមាជិកនិងសមាជិកជំនួស) នឹងទទួលបានរបៀបវារៈមួយសប្តាហ៍មុនការ ប្រជុំរបស់ពួកគេ។ សូមកត់សម្គាល់: សមាជិកតុមូលណាមួយក៏អាចស្នើសុំប្រធានបទរបៀបវារៈ ដោយផ្ទាល់ពី EPA ។

- សមាសភាពគណៈកម្មាធិការដឹកនាំ៖ EPA នឹងបង្កើតគណៈកម្មាធិការដឹកនាំមួយជាមួយសមាជិកមកពីក្រុមដែលមានការចាប់អារម្មណ៍ចំនួន ៣ ដែលបានចូលរួមយ៉ាងសកម្មនៅ ក្នុងក្រុមតុមូលរហូតមកដល់បច្ចុប្បន្នហើយដែលទំនងជាត្រូវបានរងផលប៉ះពាល់ដោយការសំអាតៈ ដូចជា អ្នកស្រុក អ្នកប្រកបជំរកម្ម/ឧស្សាហកម្ម/ពលកម្មនិងអ្នកនេសាទ។ ដូចផ្នែកទី 3B បានពិពណ៌នា ក្រុមប្រឹក្សាសហគមន៍ (CAG) ក្រុមដែលមិនមែនជាក្រុមប្រឹក្សាសហគមន៍ និងអ្នកប្រើប្រាស់ទឹកស្ទឹងសម្រាប់កម្សាន្ត តំណាងឱ្យផលប្រយោជន៍លំនៅដ្ឋាននៅក្នុង តំបន់ស្ទឹងឌូវ៉ាម មីស ភាគីទទួលដែលងាចទទួលខុសត្រូវអាជីវកម្ម (PRP)/ ឧស្សាហកម្ម /ក្រុមតំណាងការងារ និងអាជីវកម្មមិនមែនជា PRP/ឧស្សាហកម្ម/ក្រុមការងារ ដែលតំណាង ឱ្យផលប្រយោជន៍នៃអាជីវកម្ម / ឧស្សាហកម្ម / ពលកម្ម; និងជលផលតំណាងឱ្យផលប្រយោជន៍ សហគមន៍នេសាទនិងត្រីដែលជាប់ទាក់ទងនឹងស្ទឹងឌូវ៉ាមមីស។

- <u>ការតែងតាំង៖</u> សមាជិកគណៈកម្មាធិការដឹកនាំអាចត្រូវបានតែងតាំងដោយខ្លួនឯងនិង / ឬ តែងតាំងដោយក្រុមប្រឹក្សារបស់ពួកគេក្នុងអំឡុងពេលប្រជុំតុមូលឬក្នុងអំឡុងពេលការប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់ដាច់ដោយឡែក។ EPA នឹងត្រូវជូនដំណឹងអំពីការតែងតាំងទាំងនេះ។

- <u>ការប្រគល់ដំណែង៖</u> ដូចនៅលើតារាងនៅទំព័របន្ទាប់បង្ហាញថា ក្រុម CAG, ពួកដែលមិនមែនជាក្រុម CAG និងអ្នកប្រើប្រាស់ស្ទឹងសម្រាប់កំសាន្ត នឹងពិនិត្យឡើងវិញនូវការតែងតាំង និងជ្រើសរើសសមាជិកគណៈកម្មាធិការដឹកនាំម្នាក់និងម្នាក់ទៀតឆ្លាស់គ្នាដើម្បីតំណាងឱ្យផលប្រយោជន៍លំនៅដ្ឋាន។ ភាគី PRP និងអ្នកមិនមែនជាភាគី អាជីវកម្ម PRP / ឧស្សាហកម្ម / ក្រុម ប្រឹក្សាការងារនឹងពិនិត្យឡើងវិញនូវការតែងតាំងនិងជ្រើសរើសសមាជិកគណៈកម្មាធិការដឹកនាំម្នាក់ដើម្បីតំណាងផលប្រយោជន៍របស់ពួកគេនិងជម្រើសម្នាក់ទៀតជាអ្នកជំនួស និង ក្រុមជល ផលនឹងតែងតាំងសមាជិកគណៈកម្មាធិការដឹកនាំម្នាក់និងម្នាក់ទៀតជំនួសដើម្បីផល

ប្រយោជន៍សហគមន៍នេសាទនិងសហគមន៍បរិភោគត្រី។ ការទំនាក់ទំនងរបស់គណៈកម្មាធិការ EPA និងគណៈកម្មាធិការដឹកនាំ (តាមរយៈ អ៊ីម៉ែល សេចក្តីព្រាងរបៀបវារៈ ជាដើម ។ ល។ ) នឹងរួម បញ្ចូលទាំងសមាជិកគណៈកម្មាធិការដឹកនាំបឋមនិងអ្នកជំនួស។ មិនមានរយៈពេលកំណត់ទេ សម្រាប់បម្រើការនៅក្នុងគណៈកម្មាធិការដឹកនាំ។

- <u>ការកែប្រែះ</u> ជារៀងរាល់ឆ្នាំក្នុងខែមករា EPA និងក្រុមតុមូលនឹងពិនិត្យមើលសមាជិក របស់គណៈកម្មាធិការដឹកនាំដើម្បីវាយតម្លៃថា តើវាជាការសមរម្យនិងមានតុល្យភាពដល់ សហគមន៍និងភាគីដែលទទួលខុសត្រូវដែរឬអត់។ EPA សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរសមាស គណៈកម្មាធិការតាមតម្រូវការនៅពេលណាមួយរាងរាល់ឆ្នាំ។

**C.** តួនាទីរបស់សាធារណៈជន

អ្នកដែលមិនមែនជាសមាជិកតុមូល (ឧទាហរណ៍ ដូចជា សមាជិកសាធារណៈ) នឹងអាចសង្កេតមើល អង្គប្រជុំតុមូលហើយនឹងមានពេលសួរសំណួរពីរបៀបវារៈឬបញ្ចេញមតិយោបល់នៅចុងបញ្ចប់នៃការកិច្ចប្រជុំនីមួយៗ។

ដូចសមាជិកតុមូលដែរ អ្នកដែលមិនមែនជាសមាជិក ចូលរួមអង្គប្រជុំតុមូលត្រូវបានគេរំពឹងថា នឹងរក្សាបរិយាកាសប្រជុំស៊ីវិលនិងប្រកបដោយការគោរព (សូមមើលផ្នែកទី 8E សម្រាប់ច្បាប់មូលដ្ឋាន ដែលដាក់មកលើសមាជិកនិងអ្នកដែលមនិនមែនជាសមាជិក) ។ កិច្ចប្រជុំតុមូលរំពឹងថា មិនមានការ វាយប្រហារផ្ទាល់ខ្លួន ទះដៃ ស្រែកចំអក ឬទម្រង់ណាមួយផ្សេងទៀតនៃការគាំទ្រឬមិនគាំទ្រ មករំខាន នៅក្នុងកិច្ចប្រជុំតុមូល។ អ្នកដែលមិនមែនជាសមាជិកតុមូលដែលមានបំណងផ្តល់យោបល់ក្រៅផ្លូវការ នឹងគោរពតាមគោលការណ៍ច្បាប់ដូចខាងក្រោមៈ

- គេនឹងបើកពេលវេលាអោយអ្នកដែលមិនមែនជាសមាជិកតុមូលត្រឹមតែ ៣ នាទី ម្នាក់ ដែលចាប់អារម្មណ៍ក្នុងការផ្តល់យោបល់ក្រៅផ្លូវការ។.
- អ្នកបញ្ចេញមតិនឹងប្រាប់ឈ្មោះសម្ព័នមិត្ត។
- EPA និងសមាជិកតុមូលមីមួយៗមិនតម្រូវអោយឆ្លើយតបទៅនិងមតិទាំងនេះទេ។
- ឱកាសសម្រាប់អ្នកដែលមិនមែនជាសមាជិកតុមូល ផ្តល់យោបល់នៅចុងបញ្ចប់នៃកិច្ច ប្រជុំតុមូល មិនបង្កើតជាយោបល់ផ្លូវការដូចជាការផ្តល់ជូននៅក្នុងសវនាការសាធារណៈទេ។ ទោះយ៉ាងណាក៏ដោយសេចក្តីសង្ខេបនៃមតិយោបល់ពីអ្នកដែលមិនមែនជាសមាជិកតុមូលនឹងត្រូវបានកត់ចូលក្នុងកំណត់ចំណាំអង្គប្រជុំ។

តួនាទីរបស់ EPA ក្នុងការផ្តល់មូលនិធិឬស្វែងរកការគាំទ្រផ្នែកស្បៀងអាហារនិងការមើលថែទាំក្មេងត្រូវបានកំណត់ដោយច្បាប់សហព័ន្ធ។ នៅក្នុងដែនកំណត់ទាំងនេះ EPA នឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អ្នកដែល ចូលរួមនៅក្នុងកិច្ចប្រជុំតុមូលដើម្បីអោយមានស្បៀងអាហារ ការថែទាំក្មេងនិងទីតាំងប្រជុំដែល ងាយស្រួលរកដើម្បីអោយសហគមន៍ចូលរួម។

**D. <u>តួនាទីរបស់អ្នកសម្របសម្រួល</u>**

អ្នកសម្របសម្រួល ក្រោមកិច្ចសន្យារបស់ EPA នឹងដើរតួជាអ្នកផ្តល់ព័ត៍មានអព្យាក្រឹត ហើយនឹង ស្វែងរកការធានាឱ្យមានការចូលរួមប្រកបដោយសមធម៌ពីសមាជិកទាំងអស់។ អ្នកសម្របសម្រួល ក៍នឹងបង្កើនលំហូរព័ត៍មានទៅនិងមកពី EPA និងរវាងសមាជិកតុមូល។ នេះរួមបញ្ចូលទាំងការត្រួត ពិនិត្យការបកប្រែឯកសារនិងផ្តល់សេវាបកប្រែភាសានៅឯកិច្ចប្រជុំ។ នៅចុងចញ្ចប់ អ្នកសម្របសម្រួល នឹងរៀបចំសេចក្តីសង្ខេបប្រជុំនិងផ្តល់ការគាំទ្រដល់អង្គការ។ កិច្ចសន្យាសម្របសម្រួលនាពេលបច្ចុប្បន្ន គឺនៅជាមួយក្រុមហ៊ុន Triangle Associates ។

អង្គភាពផ្សេងទៀត ដូចជាកម្មវិធីស្រាវជ្រាវរបស់ UW Superfund ឬសមាជិកនិស្សិតបញ្ចប់ការសិក្សានៅ UW Graduate School ក៍អាចផ្តល់ការគាំទ្រសម្របសម្រួលដល់សមាជិកម្នាក់ៗផងដែរ។

## 8. សម្ភារៈ

**A.** រប<u>បៀបវារៈ</u>

គណៈកម្មាធិការដឹកនាំនឹងធ្វើការជាមួយ EPA និងអ្នកសម្របសម្រួលដើម្បីរៀបចំប្រធានបទប្រជុំ។ EPA នឹងធ្វើការសម្រេចចិត្តចុងក្រោយលើប្រធានបទរបៀបវារៈ។ របៀបវារៈនឹងផ្អែកលើគំរូមួយ ដែលមានផ្នែកលេចចេញជាប្រចាំដូចជាការធ្វើបច្ចុប្បន្នភាពពី EPA ការធ្វើបច្ចុប្បន្នភាពពីសមាជិក (សមាជិកក្រុមអង្គប្រជុំ ធនធានសមាជិក កុលសម្ព័ន្ធនិងសមាជិកចាំបាច់) ។ សំណួរនិងចម្លើយ; ប្រធានបទ / បញ្ហាដែលត្រូវស្វែងរកអនុសាសន៍។ និងយោបល់ / សំណួរពីសាធារណជនទូទៅ។ បញ្ជីនៃប្រ ធានបទរបៀបវារៈដែលបានស្នើនឹងត្រូវបានចែកចាយទៅសមាជិកតុមូលមួយខែមុនពេលប្រជុំតុមូល។ របៀបវារៈចុងក្រោយនិងសម្ភារៈនឹងត្រូវចែកចាយយ៉ាងហោចណាស់មួយសប្តាហ៍មុនកិច្ចប្រជុំតុមូល។

**B.** <u>ការជូនដំណឹងអំពីអង្គប្រជុំ</u>

**ការប្រជុំតុមូលនឹងត្រូវបានកត់សំគាល់តាមរយៈបញ្ជីឈ្មោះរបស់ក្រុមតុមូលនិងគេហទំព័ររបស់ក្រុមតុមូល។ វិធីជូនដំណឹងផ្សេងទៀតនឹងត្រូវបានប្រើតាមដែលគេមាន។**

**C.** <u>សង្ខេប</u>

សេចក្តីសង្ខេបនៃកិច្ចប្រជុំនឹងត្រូវបង្កើតឡើងបន្ទាប់ពីកិច្ចប្រជុំតុមូលនីមួយៗ។ ជាទូទៅសេចក្តីសង្ខេបទាំងនេះនឹងមិនផ្តល់យោបល់ដល់បុគ្គលជាក់លាក់ទេ។ ទោះយ៉ាងណាសមាជិកតុមូលអាចជ្រើស រើស “លើកំណត់ត្រា” ហើយទទួលយកយោបល់របស់ពួកគេនៅក្នុងសេចក្តីសង្ខេបប្រជុំ ប្រសិនបើមាន ការ ស្នើ សុំនៅពេលនោះ។ សេចក្តីសង្ខេបនៃកិច្ចប្រជុំតុមូលនឹងរួមបញ្ចូលនូវអនុសាសន៍តុមូលនិងចម្លើយ ឆ្លើយតបរបស់ EPA ចំពោះអនុសាសន៍តុមូលមុនៗ ប្រសិនបើត្រូវបានពិភាក្សានៅឯកិច្ចប្រជុំ។

**D.** <u>ផែនការការងារ</u>

EPA នឹងធ្វើការជាមួយគណៈកម្មាធិការដឹកនាំតុមូលដើម្បីរៀបចំផែនការការងារប្រចាំឆ្នាំ។ ផែនការការងារទាំងនេះមានគោលបំណងដើម្បីធ្វើជាគោលការណែនាំសម្រាប់ការរៀបចំផែនការតុមូលនិងការគាំទ្រផែនការរបៀបវារៈ ដោយមានការយល់ដឹងថា ការផ្លាស់ប្តូរផែនការកាងាររបស់ក្រុមតុមមូលអាចផ្លាស់ ប្តូរយោលទៅតាមកាលៈទេសៈ។

**E.** <u>ច្បាប់មូលដ្ឋាន</u>

ខាងក្រោមនេះគឺជាច្បាប់មូលដ្ឋានសម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងការប្រជុំតុមូលនីមួយៗ។ ឯកសារទាំងនេះនឹងត្រូវចុះផ្សាយនៅឯកិច្ចប្រជុំតុមូល។

ចេះគោរពគ្នា

- ឡើងនិយាយម្នាក់ម្តង។
- ស្តាប់នៅពេលដែលអ្នកដទៃកំពុងនិយាយ ចៀសវាងរំខាននិងការសន្ទនាគ្នា។
- ទុកពេលឱ្យអ្នកបកប្រែភាសា បកប្រែ។
- ស្តាប់និងគោរពមតិភាគតិច។
- សម្ព័ន្ធមិត្តល្អ ហ៊ាននិយាយចំៗ។ សមាជិកត្រូវបានលើកទឹកចិត្តមិនឱ្យព្រងើយ កន្តើយចំពោះអាកប្បកិរិយាមិនសមរម្យ

សូមអោយមានអត្ថប្រយោជន៍

- ទទួលស្គាល់ថា អ្នកចូលរួមទាំងអស់ នាំមកនូវគោលបំណង គោលដៅ ការព្រួយបារម្ភ និង ចំណាប់អារម្មណ៍ មិនថា អ្នកយល់ព្រមឬមិនយល់ព្រមជាមួយនិងពួកគេក៏ដោយ។
- ប្រព្រឹត្តដោយ“ ស្មោះត្រង់” ស្វែងរវិធីដោះស្រាយទំនាស់និងកំណត់សម្គាល់ដំណោះស្រាយ។
- វាមិនអីទេក្នុងការមិនយល់ព្រមគ្នា ប៉ុន្តែ វាមិនត្រឹមត្រូវទេ ចំពោះការវាយប្រហារផ្ទាល់ខ្លួនឬការ និយាយបង្អាច់បង្អួចដល់អ្នកដ៏ទៃ។
- កាត់បន្ថយអោយនៅតិចបំផុតចំពោះការរប្រើប្រាស់ពាក្យស្លោកនិងអក្សរកាត់ ត្រូវពន្យល់ពី និយមន័យនៅពេលប្រើវា។
- ប្រសិនបើអ្នកមានបញ្ហាជាមួយមនុស្សនរណាម្នាក់ សូមដោះស្រាយបញ្ហានេះជាមួយបុគ្គល នោះ ដោយផ្ទាល់។ ប្រសិនបើមិនអាចដោះស្រាយការខ្វែងគំនិតគ្នា សូមស្វែងរកជំនួយពីអ្នក សម្របសម្រួល។

សូមអោយមានផលប្រយោជន៍

- ចាប់ផ្តើមនិងបញ្ចប់ការប្រជុំអោយទាន់ពេលវេលា។
- គោរពពេលវេលា។
- ប្រកាន់ខ្ជាប់នូវរបៀបវារៈតាមដែលអាចធ្វើទៅបានដោយផ្តោតលើប្រធានបទអង្គប្រជុំ។

ក្រុមតុមូលនឹងពិនិត្យឡើងវិញនូវច្បាប់មូលដ្ឋានរបស់ខ្លួនបន្ទាប់ពីប្រតិបត្តិការអស់រយៈពេលមួយឆ្នាំនិង ធ្វើការកែតម្រូវតាមការចាំបាច់។

## 9. កាលវិភាគអង្គប្រជុំ

ក្រុមតុមូលនឹងជួបគ្នាបីដងក្នុងមួយឆ្នាំឬបើមិនដូច្នេះទេយល់ព្រមដោយក្រុមតុមូល។ មួយឆ្នាំម្តង នឹង មានការប្រជុំ "យ៉ាងពេញទំហឹង" ដែលស្វែងរកអោយមានការចូលរួមយ៉ាងច្រើន បំផុតដោយ សមាជិកតុមូលនិងសមាជិកក្រុមអង្គប្រជុំទាំងអស់។ ក្រុមអង្គប្រជុំនីមួយៗនឹងមានគោល បំណងជួប គ្នាយ៉ាងហោចណាស់ម្តងរវាងចន្លោះអង្គប្រជុំតុមូល។

## 10. ការកែសម្រួលទម្រង់នីតិវិធីប្រតិបត្តិការ

ទម្រង់នីតិវិធីប្រតិបត្តិការរបស់ក្រុមតុមូលនឹងបន្តដំណើរការ ដរាបណានៅមានក្រុមតុមូន។ គេនឹង ពិនិត្យវាឡើងវិញក្នុងលក្ខណៈពីរឆ្នាំម្តង។ គេអាចកែសម្រួលនីតិវិធីប្រតិបត្តិការ នៅក្នុង ឆ្នាំណាក៏បាន តាមរយៈការមូលមតិគ្នារបស់សមាជិកតុមូលនិងការយល់ព្រមពី EPA។

## 11. សេចក្តីបន្ថែម

A. រៀបចំសមាជិកគណកម្មាធិការ
B. អ្នកចូលរួមបទសម្ភាសន៍របស់អ្នកវិនិយោគ
C. គោលនយោបាយប្រព័ន្ធផ្សព្វផ្សាយ

## សេចក្តីបន្ថែម **A –** ការរៀបចំសមាជិកគណៈកម្មាធិការ

| ឈ្មោះ | សម្ព័ន្ធភាព (តាមលេខរាងនៃតួអក្សរ) |
|---|---|
| Willard Brown | Delridge Neighborhoods Development Association |
| James Rasmussen | Duwamish River Cleanup Coalition/Technical Advisory Group (DRCC/TAG) |
| Dave Gering | Manufacturing Industrial Council |
| Kevin Burrell | Seattle Public Utilities |
| Elly Hale | US EPA |
| Julie Congdon | US EPA |

DRAFT

សេចក្ដីបន្ថែម **B –** អ្នកវិនិយោគដែលត្រូវបានសម្ភាសន៍ដោយក្រុមហ៊ុន **Triangle Associates** កាលពីឆ្នាំ **2017-2018** ដើម្បីប្រមូលយកមតិលើសេចក្ដីព្រាងនីតិវិធីប្រតិបត្តិការក្រុមតុមូល។

ខាងក្រោមនេះគឺជាបញ្ជីឈ្មោះភាគីពាក់ព័ន្ធដែលក្រុមហ៊ុនភាគីទី ៣ ដែលជាក្រុមអព្យាក្រឹត *Triangle Associates* ដើម្បីសុំយោបល់របស់ពួកគេលើសេចក្ដីព្រាងនីតិវិធីប្រតិបត្តិការក្រុមតុមូល *(*ចុះថ្ងៃទី ១៣ ខែកុម្ភៈឆ្នាំ ២០១៨*)* ដែលត្រូវបានបង្កើតឡើងដំបូងគេដោយគណៈកម្មាធិការរៀបចំក្រុមតុមូល។

- Anchor QEA, LLC
- LaFargeHolcim
- City of Seattle Duwamish Valley Program
- Duwamish River Cleanup Coalition/Technical Advisory Committee (DRCC/TAG)
- Duwamish Yacht Club
- Environmental Coalition of South Seattle (ECOSS)
- King County Department of Natural Resources and Parks
- Island Tug and Barge
- Highland Park Action Committee
- Johannessen & Associates attorneys
- Nucor
- Public Health Seattle-King County
- Representative from the Lower Duwamish Waterway Group (LDWG)
- Seattle Manufacturing Industrial Council (MIC)
- Soha and Lang attorneys
- Sustainability Ambassadors
- Washington State Department of Natural Resources
- Western Tugboat Co.

សេចក្តីបន្ថែម **C -** គោលនយោបាយប្រព័ន្ធផ្សព្វផ្សាយបណ្តាញសារព័ត៌មានអាចមានការចាប់ អារម្មណ៍ចំពោះសកម្មភាពរបស់ក្រុមតុមូលទទួលបន្ទុកលើការសម្អាតចុងផ្លូវទឹកស្ទឹងខូវ៉មមីស។ បណ្តាញសារព័ត៌មានរួមទាំង ក៏ប៉ុន្តែមិនត្រូវបានកំណត់ចំពោះការចាក់ផ្សាយ ផ្នែកអេឡិចត្រូនិច និងការបោះពុម្ពទេ។ សេចក្តីព្រាងគោលនយោបាយខាងក្រោមពិពណ៌នាអំពីរបៀប ដែលក្រុមតុ មូលទទួលបន្ទុកសម្អាតផ្លូវទឹកស្ទឹងខូវ៉មមីសនឹងមានទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ។

**1.** ការស្នើសុំព័ត៌មានប្រព័ន្ធផ្សព្វផ្សាយ
ប្រធានមើលគ្រប់គ្រងគម្រោងផែនការសម្អាតចុងផ្លូវទឹកស្ទឹងរបស់ EPA នឹងទទួលខុសត្រូវក្នុង ការឆ្លើយតបទៅនឹងសំណូមពររបស់ប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងផ្លូវទឹកស្ទឹងខូវ៉មមីស។ ប្រធាន គ្រប់គ្រងគម្រោងសម្អាតនឹងប្រកាន់ខ្ជាប់នូវដំណើរការប្រព័ន្ធផ្សព្វផ្សាយផ្ទៃក្នុងរបស់ EPA ។ សមាជិក តុមូលទទួលបន្ទុកសម្អាតចុងផ្លូវទឹកស្ទឹងខូវ៉មមីសនិង/ឬអ្នកសម្របសម្រួលនឹងជូនដំណឹងដល់ប្រធានគម្រោងផែនការសម្អាតចុងផ្លូវទឹកស្ទឹងខូវ៉មមីសប្រសិនបើពួកគេទទួលបានការស្នើសុំពីប្រព័ន្ធផ្សព្វផ្សាយ។

**2.** ការធ្វើអន្តរកម្មជាមួយប្រព័ន្ធផ្សព្វផ្សាយ
ប្រសិនបើអ្នកយកព័ត៌មានម្នាក់ចុះទៅជួបផ្ទាល់ជាមួយសមាជិកនៃក្រុមតុមូលខាងផ្លូវទឹកស្ទឹងខូវ៉មមីស សមាជិកនេះនឹងនិយាយក្នុងនាមទីភ្នាក់ងារ/អង្គភាពផ្ទាល់របស់ខ្លួន ប៉ុន្តែមិនមែនក្នុងនាមជាក្រុម តុមូលទេ។ តាមតម្រូវការ EPA អាចបង្កើតសេចក្តីប្រកាសព័ត៌មានទាក់ទងនឹងក្រុមតុមូល។

**3.** ការថតរូបនិងការថតបញ្ចាំង
EPA នឹងទទួលខុសត្រូវចំពោះការឆ្លើយតបទៅនឹងសំណើសុំថតរូបឬថតបញ្ចាំងអង្គប្រជុំក្រុមតុមូល។ ក្នុងការឆ្លើយតបទៅនឹងសំណើនេះ EPA នឹងស្វែងរកការយល់ព្រមពីសមាជិកតុមូលហើយបន្ទាប់មកយល់ព្រមឬបដិសេធសំណើនេះ។

**4.** សំណើរកំណត់ត្រាសាធារណៈ
ច្បាប់ស្តីពីសេរីភាពព័ត៌មាន (FOIA) គឺជាច្បាប់សហព័ន្ធដែលផ្តល់សិទ្ធិឱ្យសាធារណៈជនធ្វើការស្នើសុំ នូវឯកសារទីភ្នាក់ងារសហព័ន្ធ។ គ្រប់ទីភ្នាក់ងារសហព័ន្ធទាំងអស់ រួមទាំង EPA ត្រូវបាន តម្រូវឲ្យ បើកចំហរដែលអាចស្នើសុំឯកសារបាន លុះត្រាតែឯកសារទាំងនោះ ត្រូវបានហាមចែករំលែកក្នុងករ ណីលើកលែងមិនអោយចែករំលែកដោយច្បាប់ FOIA ដូចជាព័ត៌មានអាជីវកម្មការសម្ងាត់ ព័ត៌មាន ការពារភាពឯកជន និងព័ត៌មានផ្សេងៗទៀត។